

**ការល្បងសិក្សា**

# អាក្បអាក្បកិរិយា នយោបាយ ខ្មែរ

## Les attitudes politiques khmères

## សេចក្ដីផ្ដើម

ជាបឋម ដើម្បីស្រួលយល់ អំពី និយមន័យ នៃពាក្យខ្មែរនិមួយៗ មាននៅក្នុង ប្រធាន-សិក្សា, យើងជូន នូវអត្ថន័យ ប្រើជាពាក្យនយោបាយដើម្បី ជាសរៀងកុំឲមាន ព្យាកុលភាព ក្នុងការយល់ន័យ ដូចយ៉ាងពាក្យៈ

- **ចរិត** (caractère) ជា ឬកពា ឬ ប្រតិកម្ម របស់ បុគ្គលម្នាក់ៗខុសផ្លែកគ្នា ដែលអ្នកដ៏ទៃ សំគាល់ ហើយ ខ្លួនឯងផ្ទាល់ ក៏ទទួលស្គាល់ **លើសលស់** (plus ou moins) វាដែរ ថាខ្លួនជាមនុស្សបែបនេះ។ បើនិយាយឲស្រួលយល់ ចរិត ជាការសំគាល់នូវ បុគ្គលិកលក្ខណៈ (personnalité) របស់មនុស្សម្នាក់ៗ ដែល អាចទុកជា សញ្ញាទៀងទាត់ នៃចរិយាសម្បត្តិរបស់មនុស្សម្នាក់ៗ។ ឧទាហរណ៍៖ មនុស្សនេះ គាត់មានចរិក ជាមនុស្សកាច។
- **ចរិយាសម្បត្តិ** (comportement) ជា ការប្រព្រឹត្ត ជាសកម្ម ឬ ជា មតិ (ការប្រព្រឹត្តដោយវាចា) របស់មនុស្សម្នាក់ៗ។ ជា ការប្រព្រឹត្ត ឆ្លើយតប ទៅនឹង ស្ថានការណ៍មួយ ដែលមានកើតឡើងចំពោះខ្លួន។ ឧទាហរណ៍៖ មនុស្សនេះ មានចរិយាសម្បត្តិជាអ្នកប្រឆាំងនឹងអ្នកប្រជាធិបតេយ្យព្រោះគាត់តែងតែប្រព្រឹត្តជាសកម្មភ្តី ជាមតិក្តី ប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ។
- **អាក្បកិរិយា** (Attitude) : ជា ចរិយាសម្បត្តិ (comportement) បង្ហាញ មនោសញ្ចេតនា ឲអ្នក

ដទៃស្គាល់ដឹង។ អាក្បកិរិយា ជា វិបរិណាម[1] អន្តរការ (variable intermédiaire) អាចពន្យល់បានអំពីការប្រព្រឹត្ត ជាវាចា ជាដំបូង កើតក្លាយ ទៅជា ការប្រព្រឹត្ត ជាសកម្ម។ បើ និយាយឲស្រួលស្តាប់គឺ គេអាចយល់បាន អំពី គំនិតរបស់មនុស្សម្នាក់  ដែលគាត់យកវា ទៅអនុវត្តន៍។ អាក្បកិរិយា មិនអាចទុកបាន ជា ចរិយាសម្បត្តិ សុទ្ធសាធនោះដែរ ទោះបី ពាក្យ អាក្បកិរិយា និង ចរិយាសម្បត្តិ គេច្រើន យកវា មកប្រើក្នុង ន័យ តែមួយក្តី ព្រោះអាក្បកិរិយា វាគ្រាន់តែជា ការប្រុងប្រៀប (disposition) ក្នុងគំនិត សំរាប់ប្រព្រឹត្ត របៀបបែបណាមួយ ដើម្បីឆ្លើយតបទៅនឹងស្ថានការណ៍មួយ ដែលមានកើតឡើងចំពោះខ្លួន។

ដូច្នេះ អាក្បកិរិយា ជា វិបរិណាម មិនប្រាកដ (variable hypothétique) ព្រោះនៅ ចំពោះមុខស្ថានការណ៍ កើតមានឡើងមួយ ដែលវា តម្រូវឲ មានប្រតិកម្ម តាមរបៀបមួយ។ ដូច្នេះ មុន មានដំណោះស្រាយ ត្រូវយកស្ថានការណ៍នោះមកធ្វើវិភាគ បែប**ភវនីយភាព**(probabilité) ដើម្បីរកកាលកំណត់ នូវវិបាកពិត របស់វា។ របៀបបែបនេះ គេអាចទុក អាក្បកិរិយា ជា ភវនិយភាព នៃការលេចធ្លោឡើង នូវចរិយាសម្បត្តិមួយ នៅចំពោះមុខ ស្ថានការណ៍មួយមានកើតឡើង។

ដូច្នេះ អាក្បកិរិយា ជា គំនិត លំដាប់ (ការរៀបចំ) ហើយនៅក្នុងនោះ មានការបែងចែក ជាច្រើន នូវ **វិវិធភាព** (variété) នៃចរិយាសម្បត្តិ ទៅតាម ការសន្មត នៃវិបាកជាភវនីយ[2]។ អាក្បកិរិយា ជា ការរៀបចំ ថាមវ័ន្ត ព្រោះវាអាចដូរ ទៅតាមការសន្មត នៃវិបាក ដែលអាចកើតមានឡើង។ ការដូរនេះឯង ដែលគេអាចទុកថា អាក្បកិរិយា វាមាន ស្ថិរភាពខ្លះដែរ នៅក្នុងការផ្លាស់ប្តូរ ជានិច្ច របស់វា។

រួមសេចក្តីមក អត្ថន័យ នៃ ពាក្យ អាក្បកិរិយា ក្នុង ប្រធាន-សិក្សា របស់យើង គឺជា ការរៀបចំ **មានសិក** (mental) និង ការរៀបចំ គំនិត កើតមានឡើង តាមការពិសោធន៍ របស់មនុស្សនម្នាក់ៗ នៅចំពោះមុខស្ថានការណ៍ ដែលមានកើតឡើងចំពោះខ្លួន។

ឧទាហរណ៍៖ អាក្បកិរិយានយោបាយ របស់ សពសីហនុ ក្នុងការ រកផលប្រយោជន៍ផ្ទាល់ គឺ ទៅតាម **វិវិធភាព** នៃការពិសោធន៍និមួយៗ ដែលព្រះអង្គធ្លាប់ជួបប្រទះវា។

---

[1] វិបរិណាម=អាចផ្លាស់ប្តូរ ឬ អាចប្រែប្រួលបាន។

[2] វិបាកជាភវនីយ= la conséquence probable។

- **ឥរិយាបថ** (posture) ជាគោលគំនិតរឹង ឬ ជំហរមាំទាំ ដែលអ្នកនយោបាយម្នាក់ៗគេប្រកាន់យក ទុកជាឧត្តមគំនិតនយោបាយ របស់គេ។ ឧទាហរណ៍៖ លោក សម-រង្ស៊ី គាត់មានឥរិយាបថ ជាអ្នកសីហនុនិយម ផ្កាប់មុខ ទោះបីមានប្រជាជនរាប់លាននាក់គាំទ្រគាត់ ក៏គាត់នៅមិនចោលឥរិយាបថនេះដែរ។

## I. និម្មិតកម្ម នៃ អាក្សកិរិយា នយោបាយ

និម្មិតកម្ម (formation) នៃ អាក្សកិរិយា នយោបាយ របស់បុគ្គលនិមួយៗ កកើត ពីកត្តាបួន៖ ១. ទម្ងន់នៃការពិសោធន៍, ២. ឥទ្ធិពល នៃកត្តា សង្គម, ៣. ឥទ្ធិពល នៃកត្តា ជីវសាស្ត្រ, ៤. ឥទ្ធិពល នៃចរិត។

### ក. ទម្ងន់ នៃ ការពិសោធន៍

ក្នុងជិវិតរស់នៅ បុគ្គលម្នាក់ៗ តែងតែមានការពិសោធន៍ ចំពោះមុខ ស្ថានការណ៍ គ្រប់បែបយ៉ាង ដែលតម្រូវឲខ្លួន មានប្រតិកម្ម ជាការដោះស្រាយក្តី ឬ ទទួលទុកនូវវិបាក នៅក្នុងចិត្តក្តី។

នៅទីនេះ យើងលើកយក ការពិសោធន៍ ធំបី យ៉ាង មកសិក្សា៖

**១**. ការពិសោធន៍ផ្ទាល់ខ្លួន ដែលបុគ្គល ម្នាក់ៗ ធ្លាប់បានជួបប្រទះ ក្នុង ឋានៈខ្លួន ជា និតិជន (sujet de droit) នៅក្នុង ការទាក់ទង ជាមួយ ជនដទៃ។

ខ្មែរយើង បានដឹងរួចហើយថា នៅស្រុកខ្មែរ តាំងពីបុរាណកាលមក ការទាក់ទងគ្នា រវាងបុគ្គលនិងបុគ្គល គឺឋិតនៅ ក្នុង ច្បាប់កម្លាំង បាយ, អំណាច និង ទំនាមទំលាប់។ ជា ទំនាក់ទំនងមាន អ្នកឈ្នះ និង អ្នកចាញ់ ជានិច្ច ដូច្នេះ ជា ទំនាក់ទំនង ជា **អំណាចនិយម** : អ្នកឈ្នះ ជា មនុស្សខ្លាំង អ្នកចាញ់ ជា មនុស្សខ្សោយ។ អ្នកឈ្នះ ត្រូវការ ឲអ្នកចាញ់ ចុះញមខ្លួនភ្លាមៗ។ ឧទាហរណ៍៖ អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ ឲ ឈ្មោះ ហ៊ុន-សែន ថា ជា «អ្នកឈ្នះឈ្នះ»។

នៅមុខ ស្ថានការណ៍មួយកើតឡើង បុគ្គលខ្លាំង គិត ហើយ ប្រព្រឹត្ត អំពើ គ្រប់បែបយ៉ាង

ដើម្បីយកឈ្នះ ហើយឈ្នះទៀត, ឯចំណែក បុគ្គលខ្សោយ គិត និង ប្រព្រឹត្ត អំពើ គ្រប់បែប យ៉ាង ដើម្បី សន្សំសុខ ដែលចាស់បុរាណខ្មែរ យក គោលការណ៍គំនិតបែបនេះ មកចងជាការ ចំណាំ ជាអមតៈនៅក្នុងសតិខ្មែរ តាមការប្រដៅថា «ខ្លួនទាបកុំកោង ដៃខ្លីកុំឈោង ស្រវា ឱបភ្នំ»។

ក្នុង ទំនាក់ទំនង ជា **អំណាចនិយម** នេះឯង វាមានឥទ្ធិពលច្រើន ទៅលើ ការកកើត អាក្បកិរិយានយោបាយ របស់ជនខ្មែរ ហើយនាំឲ បុគ្គលខ្សោយ មិនសូវហ៊ានយកចិត្តទុកដាក់ គិតពិចារណាអំពី កិច្ចការសាធារណៈ ឬ នយោបាយ នោះឡើយ។ ដូចយ៉ាងមាន ពាក្យដាស់តឿនសំរាប់កាច់ស្មារតី ប្រជារាស្ត្រថា «ម្នាក់ឯង ពុំអាច លើកភ្នំបាននោះទេ» ឬ «ប្រយ័ត្ន ស្លាប់ឥតអំបិលប្រឡាក់»

ការនេះ ជាពុម្ពមួយ និម្មិតកម្ម នៃ អាក្បកិរិយា នយោបាយ ខ្មែរ។ គោលការណ៍នេះ វារំពងនៅក្នុង សម្បជញ្ញះ ខ្មែរជំនាន់បច្ចុប្បន្ន ដែលនាំឲ ជីវិតនយោបាយខ្មែរ គ្មានការប្រែប្រួលអ្វីច្រើននោះឡើយ បើប្រៀបធៀប ទៅនឹង ប្រពៃណីនយោបាយ តាំងពីបុរាណកាលមក។ ឧទាហរណ៍៖ ក្នុងដំណោះស្រាយ បញ្ហានយោបាយ នាពេលថ្មីនេះ (២២ កក្កដា ឆ្នាំ២០១៤) លោក សម-រង្ស៊ី គាត់សុខចិត្តចុះចាញ់ លោក ហ៊ុន-សែន។ ការចុះចាញ់នេះ ធ្វើឡើងនៅក្នុង គោលការណ៍ នៃ ការទំនាក់ទំនងជា **អំណាចនិយម** នេះឯង។

**២**. ការពិសោធន៍ ដែលទុកជា **ហេតុផលសំខាន់** (enjeux) សំរាប់ជីវិតនយោបាយ ដែលទុកតម្លៃសីលធម៌ ជា មាគ៌ា សំរាប់ដឹកនាំ មនុស្សលោក។

ហេតុផលសំខាន់ សំរាប់ជីវិតនយោបាយខ្មែរ គឺ **អំណាច ដើម្បី អំណាច**។ នៅក្នុង ប្រវត្តិសាស្ត្រខ្មែរ គ្រប់សង្គ្រាម ស៊ីវិល គឺសុទ្ធតែជាសង្គ្រាម ដណ្តើមអំណាច ដើម្បី អំណាច។ គោលការណ៍នេះ វាមានឥទ្ធិពល មកលើ របៀបគ្រួតត្រា (système administratif) គឺ ការពារបក្សពួក។ រដ្ឋបាល មិនមែនគ្រប់គ្រងរដ្ឋ ដើម្បី ការពារ ប្រយោជន៍ប្រជាពលរដ្ឋ, គឺ ជារដ្ឋបាល បក្សពួកអ្នកឈ្នះ សំរាប់ការពារប្រយោជន៍ខ្លួន។

នៅក្នុង ហេតុផលសំខាន់ បែបនេះ មិនអាចបង្កើតបាន ជាដាច់ខាត នូវនិតិរដ្ឋ នោះឡើយ ហើយច្បាស់ជាគ្មាន តម្លៃសិលធម៌ ក្នុងការដឹកនាំ មនុស្សលោក នោះដែរ។

**៣**. ការពិសោធន៍ក្នុងសង្គម ដែលមាន របបនយោបាយ ជាកម្លាំងអង្គការ មានស្ថាប័ន និង

មានច្បាប់ របស់អង្គការ។

ក្នុងចំណុចនេះ ក៏គ្មានអ្វីខុស អំពីចំណុចទី២ នោះដែរ, គ្រប់ស្ថាប័ន្តរដ្ឋ និង ច្បាប់រដ្ឋ គឺ បង្កើតឡើង សំរាប់ការពារ អ្នកកាន់អំណាច និង បក្សពួកខ្លួន តែប៉ុណ្ណោះ។ សូម្បី គណបក្សប្រឆាំងក៏ គេបង្កើតវាឡើង សំរាប់ គ្រាន់តែទុកជា **សំអាងនយោបាយ** (alibi politique) ដើម្បីសំរាប់តែ តាំងឲ្យមើល ថា មាន លទ្ធិប្រជាធិបតេយ្យ នៅស្រុកខ្មែរតែប៉ុណ្ណោះ។

នៅស្រុកខ្មែរ ទ្រឹស្តី ស្តេច-ទេវរាជ្យ ជាមរតក មហាក្សត្យអង្គរ ហាក់បីដូចជា មិនទាន់ លែងប្រើនៅឡើយទេ គ្រាន់តែ អ្នកកាន់អំណាចបច្ចុប្បន្ន យកមកឆ្នៃ ជាទ្រឹស្តី អ្នកដឹកនាំជាតិ-អ្នកមានបុណ្យបារមី (gouvernant-mandat céleste ou gouvernant évènementiel) ដើម្បីឲសមស្រប ទៅនឹងលទ្ធិប្រជាធិបតេយ្យ សំរាប់អ្នកមានបុណ្យ មាន ធម្មានុរូប ដោយយកការបោះឆ្នោតគ្មានសេរី, គ្មានយុត្តិធម៌ មកបោកប្រជាពលរដ្ឋ។

## ខ. ឥទ្ធិពល នៃកត្តាសង្គម

ស្ថានភាព សង្គម របស់ជននិមួយៗ វាអាចមានទំនងដូចខាងក្រោមនេះ៖

**១**. សមាជិកភាព (appartenance)នៃ វណ្ណៈ ឬ បន ក្នុងសង្គម ដែលមាន លក្ខណវិនិច្ឆ័យ តាម **សេដ្ឋាសង្គម** (socio-économique) ឬ តាម **ភូមិសាស្ត្រសង្គម** (sociogéographique)។

នៅក្នុងសម័យព្រហ្មញ្ញសាសនា សង្គមខ្មែរ ជាសង្គមមានវណ្ណៈ (ព្រាហ្មណ, ក្សត្រីយៈ, វេសៈ និង សូទ្រៈ) តាម ពួកព្រាហ្មណ គេទុកជា ***វណ្ណវិភាគ*** (division sociale) មានសារៈប្រយោជន៍ណាស់ សំរាប់ ការរស់នៅមនុស្សលោក នៅក្នុងលោកធាតុ ដែលមានអាទិទេព ជាអ្នកបង្កើត ហើយជាអ្នកដឹកនាំ។ សុខដុម សង្គម អាចមានបាន លុះត្រាតែវណ្ណៈនិមួយៗ យល់ដឹង និង ទទួលយក នូវតួនាទីរបស់ខ្លួន ដោយពេញចិត្ត ព្រោះវាជាឆន្ទៈរបស់អាទិទេព។ នៅក្នុង វណ្ណវិភាគនេះ វាគ្មានសញ្ញាណ ជិះជាន់ និង ការផ្តៀតរកកម្រៃ រវាងវណ្ណៈនោះឡើយ។ វណ្ណៈនិមួយៗ រស់នៅដាច់ពីគ្នាតែ មានចំណងនឹងគ្នា តាម ប្រយោជន៍សាធារណៈ ឬ ប្រជាប្រយោជន៍ ជាខ្សែអន្ទងចាំបាច់ សំរាប់ ដំណើរ ដំរលូន នៃ សង្គម។ **ទិដ្ឋិ** (dogme) នេះមានសារៈប្រយោជន៍ណាស់ សំរាប់របបរាជាធិបតេយ្យខ្មែរ ដែលទុក តួនាទី វណ្ណៈក្សត្រីយៈជាឆន្ទៈរបស់ព្រះអាទិទេព។

ដូចបានជំរាបខាងលើរួចមកហើយ ថាការទំនាក់ទំនង បុគ្គល និង បុគ្គល នៅក្នុងសង្គមខ្មែរ

គឺឈរលើ ទំនាក់ទំនង **អំណាចនិយម** ដូច្នេះឯង មហាក្សត្យខ្មែរ ព្រះអង្គ តែងតែ យកតួនាទី របស់ខ្លួន មកប្រើជាអំណាច គ្រប់សង្កត់ ប្រជារាស្ត្រ។ ការបំបែរចេញ ពីករណីយកិច្ចខ្លួន (prévarication) នេះ ជារូបភាព នៃអំពើពុករលួយ ដែលជាលំអានមួយ ដែល អ្នករាជការគ្រប់ ជាន់ថ្នាក់ យកមកធ្វើតាម បង្កើតបានជា វប្បធម៌ជាតិ គឺ «អំពើពុករលួយ»។ ក្រោយមក ទៀត វណ្ណៈ ក្លាយជា បនបិទទ្វា (bande fermée) មាន បនរាជវង្សានិវង្ស, បនគ្រួសារអ្នកកាន់ អំណាច មានងារជាសម្តេច, បនឈ្មួញទុច្ចរិត ឬ ឧកញ៉ា, បនមន្ត្រីពុករលួយ, បនអ្នកនយោ បាយស៊ីពៃ មានងារជាឯកឧត្តម, ចំណែកអ្នកស្លូតត្រង់ និង អ្នកខ្សោយ ក៏ក្លាយ ជាឧបករណ៍ សំរាប់ បននិមួយៗយកមកប្រើ ដើម្បីរកប្រយោជន៍ឲគេ។ នុះ (ainsi) សង្គមខ្មែរ នាបច្ចុប្បន្ន នេះ មាន **រូបសាស្ត្រ** (morphologie) ជាសង្គមសក្តិភូមិ ដូចពីបុរាណកាលនោះដែរ។ ឥទ្ធិពល កត្តាសង្គមបែបនេះ វាមានឥទ្ធិពល មកលើ អាក្សកិរិយានយោបាយ របស់ អ្នកដឹកនាំជាតិ និង វរជនខ្មែរ ខ្លាំងណាស់, ជាឧបសគ្គ ដើម្បីស្ថាបនា លទ្ធិប្រជាធិបតេយ្យសេរី ដែលជាផ្លូវតែ មួយគត់សំរាប់ ស្វែងរក ការចំរើន នៃមនុស្សលោក និង សង្គមជាតិ។

ភាពខុសគ្នា នៃការរស់នៅ របស់ ប្រជាជន ទីជនបទ ដែលជាអ្នកកសិករ, ប្រជាជន ចំការរស់ តាមដងទន្លេ, ស្ទឹង និង ប្រជាជន ទីក្រុង ដែលជាអ្នករាជការ, ឈ្មួញមានដើមកំណើតជាចិន, ពលករ ជំនាញគ្រប់វិស័យ មានដើមកំណើតជាយួន ជាកត្តាបែកចែកសង្គមខ្មែរជាពីរ ភូមិ សាស្ត្រសង្គម ដែលខ្មែរយើងច្រើនហៅថា ពួកអ្នកស្រែ និង ពួកអ្នកទីក្រុង។ ការបែងចែកនេះ មានស្នាមនៅក្នុងប្រវត្តិសាស្ត្រខ្មែរយូរយារមកហើយ ដូចយ៉ាងខ្មែរ ទុកជានិច្ច មជ្ឍមណ្ឌល អំណាចជា «បូរី» ឬ «ក្រុង»។ ពាក្យក្រុងចំពោះខ្មែរ មានន័យទូលំទូលាយណាស់។ ទីក្រុង គឺជា តំណាង នៃវប្បធម៌ តែម្តង, ឯចំណែក ទីជនបទ គឺជាតំណាង នៃភាពល្ងង់ខ្លៅ ឬ មិនទាន់ សម័យ, រហូត អ្នកទីក្រុង បើគេចង់ប្រមាថ បុគ្គលណាម្នាក់ដែលគ្មានចំណេះ ឬ ល្ងង់ គឺគេ ប្រដូចបុគ្គលនោះ ទៅនឹង អ្នកស្រែ ដោយគេជេរថា អាហ្នះ ល្ងង់មើលតែអ្នកស្រែ ឬ អាសម្រែ។ តែបើយើង យកគោលការ នៃ ទំនាក់ទំនង ជាអំណាចនិយម ដូចបានរៀបរាប់ខាងលើរួច មកហើយ មកធ្វើជាយោង នៃ ទំនាក់ទំនាក់ ទីក្រុង និង ទីជនបទ គឺវា ជាទំនាក់ទំនង **ចុះ នាម**(s'inscrire) នៅក្នុង ទំនាក់ទំនង នៃ អំណាចនិយម នេះឯង។

**២**. សមាជិកភាព នៃ សមាគម ដូចយ៉ាងះ ក្លឹប, សហជិប, ចលនា ។ល។ ប្រដូចបាន ជា អង្គ

ការ (groupe organisé) ទំនើប ឬ របស់ថ្មីមួយ សំរាប់ ប្រជាពលរដ្ឋខ្មែរ ព្រោះវាជាអង្គការ នៅក្រៅរដ្ឋ និង គ្រួសារ។ អង្គការទាំងនេះ មានដើមកំណើតនៅបស្ចិមប្រទេស ជាពិសេស កើតមានឡើងច្រើន ក្នុងសម័យ បដិវត្តន៍ ឧស្សាហកម្ម នៅក្នុងកំឡុង សតវត្ស ទី១៨-១៩ មានធាតុ ជាអង្គការ ការពារ ប្រយោជន៍ នាយទុន (ក្លឹប), ទាមទារសិទ្ធិ កម្មករ (សហជិប), តស៊ូប្រឆាំងនឹង នាយទុន ឬ អំណាចផ្តាច់ការ (ចលនា)។ នាបច្ចុប្បន្ននេះ នៅក្នុង **គ្រោង សាកលលោកតែមួយ** (cadre de mondialisation) មាន បង្កើត អង្គការថ្មីមួយទៀត មានឈ្មោះថា អង្គការក្រៅរដ្ឋាភិបាល (O.N.G) ដែលមាន បេសកកម្ម ការពារ មនុស្សជាតិ។ ប្រជាពលរដ្ឋខ្មែរ ទើបតែ ចាប់អារម្មណ៍បន្តិចម្តងៗ អំពី ប្រយោជន៍ នៃ អង្គការទាំងឡាយនោះ ជាពិសេស ប្រជាជន ជាពលករ ដែលទទួល រងគ្រោះ អំពី អំពើអយុត្តិធម៌ គ្រប់បែបយ៉ាង ពីសំណាក់នាយទុន តែការចាប់អារម្មណ៍នេះ នៅក្នុងដំណាក់កាល ជា**ការប្រព្រឹត្តមតិ** នៅឡើយ ព្រោះខ្មែរម្នាក់ៗ មិនទាន់មាន ទំលាប់ ប្រើកម្លាំងក្រុម ជាកម្លាំងការពារសិទ្ធិ និង ប្រយោជន៍បុគ្គល និង ប្រយោជន៍រួម។ ចំពោះខ្មែរម្នាក់ៗ ពាក្យក្រុម គឺ គ្រួសារនេះឯង តែគេដឹងថា ប្រយោជន៍គ្រួសារជាប្រយោជន៍ឯកជនព្រោះដែន (champ) ប្រយោជន៍គ្រួសារ មានវង់តូចណាស់ មិនអាចទុកជាប្រយោជន៍រួមបាននោះទេ។ តែនៅក្នុងប្រយោជន៍រួម បើគ្មានផលប្រយោជន៍ បុគ្គល ជាចំណែក ប្រយោជន៍រួមនោះ វាគ្មានខ្លឹមសារអ្វី សំរាប់មនុស្សលោក នោះឡើយ។

មួយវិញទៀតជីវភាពរស់នៅ របស់ប្រជាជនខ្មែរភាគច្រើន រស់នៅក្នុង សេចក្តីត្រូវការ ***ជីវសាស្ត្រ*** (besoin biologique) ឬ បញ្ហាអត់ឃ្លាន និង សេចក្តីត្រូវការ ***សុវត្ថភាព*** (besoin de sécurité) ឬ បញ្ហាលំនៅដ្ឋាន ដូច្នេះ ជនខ្មែរគ្មានអារម្មណ៍អ្វី គិតលើស អំពីបញ្ហាសំខាន់ទាំងពីរនេះឡើយ ព្រោះជាបញ្ហាជីវិតរស់នៅគ្រប់ទិវារាត្រី, ដែល លោក Maslow វិទូសង្គមសាស្ត្របរទេសមួយរូប បែងចែក សេចក្តីត្រូវការរបស់មនុស្សលោក ជា៥ ចំណង់៖

១/ សេចក្តីត្រូវការ ជីវសាស្ត្រ (besoin biologique) ឬ បញ្ហាអត់ឃ្លាន។

២/ សេចក្តីត្រូវការ សុវត្ថភាព (besoin de sécurité)។

៣/ សេចក្តីត្រូវការ សមាជិកភាព (besoin d'appartenance) ឬ ចំណង់ចូលរួមសកម្មភាព នៅក្នុងក្រុម ឬ អង្គការណាមួយ។

៤/ សេចក្តីត្រូវការ ការរាប់អានពីអ្នកដទៃ (besoin d'estime)។

៥/ សេចក្តីត្រូវការ បង្កើតអ្វីមួយដោយខ្លួនឯង (besoin autocréation)។

ន្ទុះ ឥទ្ធិពល សមាជិកភាព នៃ សហជិប, ចលនា ចំពោះ ពលករ គ្មានមានច្រើនក្នុង និម្មិតកម្ម នៃអាក្បកិរិយានយោបាយ នោះឡើយ។ បើមានខ្លះ គឺមានក្នុង ចរិយាសម្បត្តិ ដូចជា សេចក្តីស្អប់ ចំពោះនាយទុន និង កម្មផល របស់ខ្លួនតែប៉ុណ្ណោះ តែសេចក្តីស្អប់នេះ មិនទាន់មាន ការប្រព្រឹត្តជាសកម្ម ជាក់ស្តែង សំរាប់ ការពារខ្លួនឯងនោះដែរ ទោះបី យើងឃើញមាន បាតុកម្ម ទាមទារ តម្លើងប្រាក់ខែ, ការពារសិទ្ធិកម្មករ។ល។ តែសកម្មភាពទាំងនេះ នៅមានកំរិត តិចតួចណាស់ ហើយ ដាច់ៗពីគ្នាផង ដែលជាកម្លាំង មិនទាន់មានការរៀបចំនៅឡើយ។

**៣**. សមាជិកភាព នៃ **ក្រុមបឋម** (groupe primaire) ក្នុងនោះ សមាជិកនិមួយៗ មានការ ទំនាក់ទំនង ផ្ទាល់ ហើយ ញឹកញាប់ ជាទីបំផុត ដែលគេឲឈ្មោះថា **ទំនាក់ទំនង ទល់មុខគ្នា** (relation face à face)។

ក្រុមបឋម គឺជា គ្រួសារ អ្វីដែលជិតស្និត ខ្មែរយើង ទុកជាគ្រួសារ។ ក្នុងភាសាខ្មែរភរិយា ស្វាមី ក៏គេហៅថា គ្រួសារដែរ។ សមាសភាពនៃគ្រួសារ ជាការផ្សំមាន **ឋានានុក្រម**[3] មាន មេ ដែលជាបិតា (ឬ មាតា ក្នុងសម័យដើមខ្មែរ ដែលជាសម័យ មតេយ្យាកា)។ ន្ទុះ មតិ,យោបល, គំនិត របស់ មេ ជា ផ្នត់គំនិត របស់គ្រួសារតែម្តង។ អាក្បកិរិយានយោបាយរបស់ មេ គ្រួសារ ជាអាក្បកិរិយានយោបាយ របស់សមាជិកនៃគ្រួសារ។

ពាក្យគោរពប្រតិបត្តិចំពោះមេ គឺតម្រូវឲបុគ្គលម្នាក់ៗ បោះបង់ចោលទាំងអស់ នូវវិចារណញ្ញាណ ផ្ទាល់ខ្លួន ; អ្វីដែលជាយោបល់ គឺជាការប្រមាថមើលងាយដល់មេ។ មេ ទុក អ្នកដែល នៅក្រោមអានុភាពរបស់ខ្លួន ជា កូនចៅ របស់ខ្លួន រស់នៅក្រោមឱវាទខ្លួនជាដាច់ខាត។ ខ្មែរមានការស្មោះត្រង់ គ្មានល័ក្ខខណ្ឌ ចំពោះ មេ, ព្រោះ មេ គឺ ជាអ្វីគ្រប់បែបយ៉ាងសំរាប់ ខ្លួន (le Chef est tout pour lui) ; មានបុណ្យស័ក្តិ គឺដោយសារ ការគោរព និង ការស្មោះត្រង់ ចំពោះ មេ ដូច្នេះត្រូវដឹងគុណមេ អស់មួយជីវិត ពុំនោះសោធ បុណ្យស័ក្តិនោះ មិនអាចគង់វង់ បាននោះឡើយ។

ឧទាហរណ៍៖ បើបានងារស័ក្តិយស ចិត្តឲស្មោះនឹងមហាក្សត្យ បើចង់គង់សម្បត្តិ ច្បាប់លោក

---

[3] ឋានានុក្រម=la composition hiérarchisée។

ថា កុំសូវចាយ។ ការទូន្មានបែបនេះ គឺជា ការយក «ភាពជាក់ស្តែង[4]» មកធ្វើជា កាតព្វកិច្ច។

## គ. ឥទ្ធិពល នៃកត្តា ជីវសាស្ត្រ

ដែល វិទូនយោបាយ គេឲឈ្មោះថា **បរិយាការណ៍កាយា** (ambiance corporelle)។ គេអាច ធ្វើវិភាគ អាក្យកិរិយានយោបាយ តាម បរិយាការណ៍កាយា នេះ ដូចយ៉ាង៖

**១**. ឥទ្ធិពល នៃ ចរិកលក្ខណ: នៃ**ជីវសាស្ត្រសង្គម** (bio-sociales) ដូចជា អាយុ, ភេទនិងអំបូរ។

**២**. ឥទ្ធិពល នៃ យន្តការ (mécanisme) ធ្វើឲទៀងទាត់ នៃ ជីវិត និង សុខភាព។

ខ្មែរឲសារៈសំខាន់ណាស់ទៅលើអំបូរ ; បើទុកដាក់កូនចៅឲមានគូរស្រករ គេតែងតែមើលពូជអំបូរគ្រួសារ ហេតុនេះឯងបានជាពូជអំបូរគ្រួសារ មានឥទ្ធពលទៅលើអាក្យកិរិយានយោបាយដល់បុគ្គល។ សម័យសក្តិភូមិ បើស្តេចចោទអ្នកណាម្នាក់ថាក្បត់ជាតិ គឺព្រះអង្គមិនមែនយកជនក្បត់នោះទៅសម្លាប់ចោលតែម្នាក់ឯងនោះទេ គឺព្រះអង្គបញ្ជាឲសម្លាប់ញាតិប្រាំពីរសន្តានឲអស់ ទើបអាចស្ងប់កំហឹងព្រះអង្គបាន។

ខ្មែរយើងគោរពចាស់ទុំណាស់។ ឧទាហរណ៍៖ «រៀនបទរៀនបាន កុំកោងហួសខ្នាត កុំភ្លាត់ខុសផ្លូវ កុំប្រហើនភ្លេចម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ កុំត្រូវមើលងាយ»។ មកដល់ចំណុចនេះ យើងលើកយកទ្រឹស្តី លោក កេង-វាន់សាក់ ស្តីពី វប្បធម៌ខ្មែរដើម[5] មកបញ្ជាក់អំពីការគោរពចាស់ទុំ ដែលជាការគោរពមួយមានលក្ខណ: ជាការគោរព ឈរលើការពិសោធ ជាការពិត មិនមែនផ្អែកទៅលើ ជំនឿសាសនា ឬ គ្មានហេតុផល។ វប្បធម៌ដើមនេះ លោក កវី[6]ឲឈ្មោះថា ការគោរពបូជា «**មេ-បា**»។ វប្បធម៌ខ្មែរដើមនេះ មានទិដ្ឋភាពស្រួលប្រើក្នុងការរស់នៅរបស់មនុស្សលោកនៅក្នុង **នរសង្គម** (société humaine) ណាស់ ដែលលោក កវី ទុកជាគ្រឹះនៃសង្គមខ្មែរ អាចប្រឈរមុខ ទប់ទល់នូវការហូរចូល នូវប្បធម៌បរទេសបាន ជាពិសេស វប្បធម៌ឥណ្ឌា នោះឯង ; ដូចយ៉ាង យកវប្បធម៌ឥណ្ឌា មកកែឆ្នៃឲមាននូវភាពជាខ្មែរ (ខ្មែរូបនីយកម្ម) សំរាប់ស្រួលក្នុងការប្រតិបត្តិ នៅក្នុងសង្គមខ្មែរ។ តាមមតិ លោក កេង វាន់សាក់ ការ

---

[4] ការជាក់ស្តែង= l'évidence។

[5] វប្បធម៌ខ្មែរដើម គឺវប្បធម៌របស់ជនជាតិខ្មែរមានមុនពីការហូរចូលវប្បធម៌ឥណ្ឌាចូលមកស្រុកខ្មែរ។

[6] កវី នៅទីនេះ ប្រើក្នុងន័យថា មនុស្សមានប្រាជ្ញា ឬ ប្រកបដោយគតិបណ្ឌិត។

មាន សមត្ថភាពកែច្នៃនេះឯងហើយ ដែលយើងអាច ទុកជា ទេពកុសលខ្មែរ នៅក្នុងជំនាន់នោះ។ តើ ក្នុងបច្ចុប្បន្ននេះ ខ្មែរយើង អាចនៅមាន ទេពកុសល បែបនេះទៀតដែរឬទេ ? ចាប់ពីសតវត្សទី១៥មក ការរស់នៅរបស់ប្រជាជនខ្មែរ មានការរីកររខ្លាំងណាស់ ដោយសារប្រទេសមានសង្គ្រាមស៊ីវិលផង សង្គ្រាមវាតទឹកដី ពីសំណាក់ប្រទេសជិតខាងផង។ ខ្មែរនាំគ្នារត់គេចសង្គ្រាម ពីដំបន់មួយ ទៅដំបនមួយ នាំគ្នាហាលបាយសំរាប់បរិភោគ ដែលខ្មែរយើងហៅថា បាយកាតាក ព្រោះគ្មានលទ្ធភាពធ្វើស្រែចំការសំរាប់ចិញ្ចឹមជីវិត។ យុវជន និង ជនមានវ័យមធ្យម ដែលជាពលកម្ម សំរាប់គ្រួសារ ត្រូវអាជ្ញាធរកេណ្ឌធ្វើទាហ៊ាន ទៅច្បាំងជួយការពារជាតិ ជួនកាល ការពារប្រយោជន៍បុគ្គល ទៅតាមជាតុនៃសង្គ្រាម។ ដោយមានសង្គ្រាមកើតមានឡើងលើសលុប ខ្មែរទាំងចាស់ក្មេង ស្រីប្រុស នាំគ្នារត់ពួនក្លាចអាជ្ញាធរ កេណ្ឌបញ្ចូលទៅក្នុងភារិកម្ម (corvée) សង្គ្រាម ពួនសម្ងំចាំមើលស្ថានការសិន។ ការរង់ចាំនេះ វាមានឥទ្ធពល ទៅលើ អាកប្បកិរិយានយោបាយជនខ្មែរម្នាក់ៗ គឺ **គំតិនិច្ចលនិយម** (l'immobilisme d'esprit) ដែលជារូបភាពនៃសេចក្តីខ្លាច និង ការរង់ចាំ។ គំនិតនេះ ជាកំណើត នៃ ***វប្បធម៌ធ្វើសិន*** ដូចយ៉ាង «ចាំមើលសិន តើនរណាជាអ្នកឈ្នះ...» «ធ្វើសិនទៅ ស្អែកសុំគិតទៀត»។ ឧទាហរណ៍ជាក់ស្តែង គឺ កិច្ចព្រមព្រៀង ថ្ងៃទី២២ កក្កដា រវាង សម-រង្សី/កែម-សុខា ជាមួយហ៊ុន-សែន ; ចំពោះ សម-រង្សី និង កែម-សុខា ដំណោះស្រាយរបស់គាត់ គឺផ្អែកលើ «វប្បធម៌សិន» នោះឯង។

***អ្វីជា វប្បធម៌សិន ?*** ជាអំពើមួយធ្វើឡើង គ្មាន ការត្រិះរិះ គឺធ្វើសំរាប់តែធ្វើ គ្មានដើម គ្មានគោលដៅ បើមានកើតហេតុអ្វី សុំនាំគ្នា ធ្វើអ្វីមួយផ្សេងទៀត។ នេះជាគំនិត **គតិនិច្ចនិយម** នោះឯង។ បើនិយាយឲស្រួលយល់ វប្បធម៌ធ្វើសិន គឺ «ការថ្កិនភ្នែក» ឲគេមើលឃើញថា កំពុងធ្វើ តែការពិត ទង្វើនេះជា មាយាការ តែប៉ុណ្ណោះ។ ដូច្នេះ វប្បធម៌ សិន មានធាតុអវិជ្ជា ពីរយ៉ាង ៖ ខ្លាច និង សេចក្តីធ្វេសប្រហែស។ ខ្លាច ព្រោះធ្លាប់មានទុក្ខ ; សេចក្តីធ្វេសប្រហែសព្រោះគិតតែប្រថុស ដើម្បីយករស់មួយគែសិន។

## ឃ. ឥទ្ធិពល នៃចរិត

ចរិតមានគ្រិះធំបីយ៉ាង៖ **អារេគភាព** (émotivité) ឬ ចិត្តឆាប់រំភើប, **សកម្មភាព**

(activité) ឬ រហ័សរហួន និង **ដំណើរលាន់រំពង** (retentissement) ឬ អួតក្អេងក្អាង។ គ្រឹះទាំងបីនេះ ផ្សំគ្នាបង្កើតបានជា គំរូ ចរិត ប្រាំបី យ៉ាង យោងតាម **មនោគតិវិធី** (méthode analytique) ដែលគេយកតួអក្សរ E, A, P, S ជាសំគាល់៖

**E** : Emotif ; **A** : Actif ; **P** : Retentissement qui ne dépasse guère le présent ; **S** : Retentissement chez qui le retentissement se prolonge longuement។

E : អារម្មណ៍ ឬ ការងាយរំជួលចិត្ត ; nE : ការមិនសូវរំជួលចិត្ត។

A : សកម្ម ; nA : មិនសូវសកម្ម។

P : ដំណើរលាន់រំពង ដែលមានរយៈខ្លីបំផុត។

S : ដំណើរលាន់រំពង ដែលមានរយៈយូរ។

ផ្អែកលើគោលធំៗខាងលើនេះ គេឲអត្ថន័យវា ដូចខាងក្រោមនេះ៖

១. Les nEnAP : ចរិត គ្មានសណ្ឋានប្រាកដ (amorphes) ;

២. Les nEnAS : ចរិត ស្ពឹក (apathiques) ;

៣. Les nEAP : ចរិត ឆាប់ខឹង (sanguins) ;

៤. Les nEAS : ចរិត ធ្មើង ឬ មិនសូវនិយាយស្តី (flegmatiques) ;

៥. Les EnAP ចរិត មួម៉ៅច្រើន (nerveux) ;

៦. Les EnAS : ចរិត បញ្ចេញមនោសញ្ចេតនា ឬ រំភើបចិត្ត (sentimentaux) ;

៧. Les EAP : ចរិត កំហឹងឆួល ឬ ចិត្តស្រាល (colériques) ;

៨. Les EAS : ចរិត ចូលចិត្តខ្លាំង ឬ ស្រឡាញ់ងប់ (passionnés) ។

ទីនេះ យើងមិនលើកយកវគ្គខាងលើនេះមក អធិប្បាយឲល្អិតល្អន់នោះទេ ព្រោះបើចង់ដឹងច្បាស់នូវចរិតបុគ្គលម្នាក់ៗ ត្រូវចាំបាច់ធ្វើការសិក្សាបែបមនោវិភាគលើបុគ្គលនិមួយៗ។ ដូច្នេះ យើងគ្រាន់តែលើកមកបង្ហាញអំពី គ្រឹះនៃចរិតមនុស្សម្នាក់ៗតែប៉ុណ្ណោះ ដើម្បីទុកជាការចេះដឹងទូទៅ ឬ វប្បធម៌ទូទៅ ឬ សំរាប់សំគាល់ជាទូទៅអំពីចរិតអ្នកនយោបាយខ្មែរ ដោយយោងតាមសកម្មភាពជាសាធារណៈ របស់គាត់។

លោក ប៉ុន-ចន្ទមុំល នយោបាយវិទូខ្មែរម្នាក់ បានលើកយកចរិតខ្មែរ ឬ អកប្បអាក្បកិរិយាខ្មែរ មកអធិប្បាយយ៉ាងក្បោះក្បាយក្នុងសៀវភៅលោក (ចរិតខ្មែរ)។ ចរិតអវិជ្ជាទាំងនោះគឺ៖

មានតែអញ្ញ, លួចយកយោបលគេ, គ្មានពិគ្រោះសាកសួរខ្លាចនយោបាយ, សងសឹកសួរពូជ, ផ្តាញ់ផ្តាល,លោភពង្រិចពង្រីល និង ចង្រៃ។
យើងយកការសិក្សា លោក ប៊ុន-ចន្ទម៉ុល ធ្វើជាយោងមួយដែរ ដើម្បីលាតត្រដាងបន្ថែម អំពីអាក្យកិរិយានយោបាយខ្មែរ សំរាប់ទុកជា **គោលសំរាប់អាន** (grille de lecture) ដើម្បី យល់ដឹងច្បាស់អំពីសកម្មភាពនយោបាយ របស់អ្នកនយោបាយខ្មែរ។

## II. តួនាទីនៃ មនោគមវិជ្ជានយោបាយ

គួរលើកយកតួនាទី មនោគមវិជ្ជា មកអធិប្បាយដែរ នៅក្នុងការសិក្សា អំពីអាក្យកិរិយានយោបាយខ្មែរ។ យើង ធ្លាប់បានសាកល្បងសិក្សាលំអិតរួចម្តងហើយ នៅក្នុងការល្បងសិក្សារបស់យើង មានចំណងជើងថា «**សតវត្សអធម៌**»។
វិទូនយោបាយខ្លះ សង្ខេបជារូបមន្តថា នយោបាយ ជា«គំនិត», អ្នកខ្លះ ទុកមនោគមវិជ្ជា ជា វិវាទនយោបាយ ប្រើសម្ភារៈគ្រប់បែបយ៉ាង ដើម្បីដណ្តើមអំណាច, មួយក្រុមទៀត មានយោបល់ថា មនោគមវិជ្ជា ជា ការជំទាស់ខ្លាំង នៃចរិត រវាង បុគ្គល។ ទសន្ស:ទាំងបីនេះ សុទ្ធតែមានខ្លឹមសារ ចងគ្នាទៅវិញទៅមក ខ្វះកត្តាណាមួយ គឺអាចនាំឲអ្នកសិក្សាអំពីមនោគមវិជ្ជានយោបាយ មើលឃើញមិនអស់ នូវសារជាតិរបស់វា។
តែយើង ដឹងថា ប្រើពាក្យ គំនិត នយោបាយ វាងាយយល់ជាង ប្រើពាក្យ មនោគមវិជ្ជានយោបាយ ព្រោះពាក្យ គំនិត លើកបង្ហាញ សញ្ញាណ ច្បាស់លាស់ ថា ចង់ធ្វើអ្វីមួយច្បាស់, ឯចំណែក មនោគមវិជ្ជា មានសញ្ញាណ អរូបី អាចបង្កើត ជាព្យាកុលភាពសំរាប់ យល់ដឹងអំពីគោលបំណង។ តែ នៅពេល មនោគមន៍វិជ្ជា មានប្រភព កើតចេញពីគំនិតនយោបាយមួយ, ដែលគេទុកជា **ភាវៈសុទ្ធសាធ នៃផលិតបញ្ញា** (produit intellectuel à l'état pur) មកប្រែសំរាប់ សំគាល់ជាធាតុរបស់ខ្លួន ហើយធាតុនោះ វាជ្រួតជ្រាបជាគំនិតរួម ងាយយល់ និង ខុសអំពីភាពដើមរបស់វា នៅពេលនោះមនោគមវិជ្ជា វាផ្តិតជាប់ក្នុងគតិ នៃមនុស្សមួយក្រុម ដែលមានជំនឿរួមងប់ទៅលើគំនិតរួមនោះ។ ហេតុនេះឯង គេច្រើនប្រើពាក្យ គំនិតនយោបាយ សំរាប់សំគាល់ គំនិតបុគ្គលម្នាក់ ឯចំណែក ពាក្យមនោគមវិជ្ជា គឺសំដៅទៅលើគំនិតនយោបាយ របស់ក្រុមមួយ ដែលគេប្រដូចនឹងពាក្យ លទ្ធិ (doctrine) នយោបាយ នោះដែរ។

តែវិភេទ នៃពាក្យ គំនិតនយោបាយ និង មនោគមវិជ្ជា គឺជាការសន្មតសុទ្ធសាធ។ ពេលណា គេប្រើពាក្យមនោគមវិជ្ជា គឺ គេចង់សង្កត់ អំពីគំនិតនយោបាយ ជាប់ទាក់ទង ទៅនឹងទំហំ នៃបញ្ហាសង្គម ឬ ចង់សង្កត់លើ រូបតំណាង នៃបញ្ហា របស់គណបក្សនយោបាយ, ក្រុម, ការពិសោធនយោបាយ ឬ ស្នាដៃនិពន្ធន៍នយោបាយដ៏សំខាន់ (grands œuvres politiques) ណាមួយ។

នុះ មនោគមវិជ្ជា វាមានឥទ្ធពលទៅលើ អាក្បកិរិយានយោបាយ នៃបុគ្គលម្នាក់ៗ ដែលជាប់ចិត្តដោយពេញចិត្ត ទៅលើគំនិត ឬ មនោគមវិជ្ជា ណាមួយ មាននៅក្នុងសង្គម ដែលខ្លួនកំពុងរស់នៅ។

នៅក្នុងប្រវត្តិសាស្ត្រនយោបាយខ្មែរ យើង ឃើញមាន មនោគមវិជ្ជា ដែលខ្មែរភាគច្រើនទុកជាមនោគមវិជ្ជាជាតិ គឺ រាជានិយម និង ពុទ្ធសាសនា បន្ទាប់មក មាន លទ្ធិសីហនុនិយម ដែលជា **ប្រពន្ធស្ថិរភាព** (système de cohérence) ដែលជាប្រពន្ធ គ្រប់គ្រងសង្គមខ្មែរ រហូតមកដល់បច្ចុប្បន្នកាល ទោះបី ប្រពន្ធស្ថិរភាពនេះ ជាប្រពន្ធមួយ ផ្ទុយពី លទ្ធិប្រជាធិបតេយ្យសេរីក៍ដោយ។

នៅក្នុងសតវត្សទី២០ យើង ឃើញមានការប៉ុនប៉ងដូរ ប្រពន្ធនេះដែរ ដូចមាន នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧, ការប្រកាសរបបសាធារណរដ្ឋ ក្នុងឆ្នាំ១៩៧០, ការកាន់អំណាច បក្សកុម្មុយនិស្តខ្មែរ ដែលយើងហៅថា របបខ្មែរក្រហម ក្នុងឆ្នាំ១៩៧៥។ តែ ការប៉ុនប៉ងទាំងឡាយនេះបានទទួលបរាជ័យនៅចំពោះមុខ នយោបាយវាតទីកដីយួនកុម្មុយនិស្ត ក្នុងឆ្នាំ១៩៧៩។ ជ័យជំនះនេះ ហាក់បីដូចជាក្លាយជា ជោគជ័យ ជាស្ថាពរ របស់ បក្សកុម្មុយនិស្ត វៀតណាម ក្នុងគោលបំណងបង្កើតសហពន្ធឥណ្ឌូចិនថ្មីមួយ ដែលមានខ្លួនជាអ្នកគ្រប់គ្រង។ នៅក្នុងមហិច្ឆតានេះ អ្នកដឹកនាំជាតិវៀតណាម យកទ្រឹស្តី **ការពិតសង្គម** (réalité social) ស្តីពី ចលនា នៃគំនិត មកអនុវត្តន៍។ ទ្រឹស្តីនេះ ឈរលើ ការទុក មនោគមវិជ្ជាកុម្មុយនិស្ត និង វប្បធម៌ជាតិសាសន៍យួន ជា វត្ថុធាតុ មានគុណភាព ខ្ពស់ជាងគេបង្អស់ នៅដំបន់ឥណ្ឌូចិន។ យុត្តិកម្ម នេះ ជា ធម្មានរូប របស់ ប្រទេសវៀតណាម ក្នុង ការគ្រប់គ្រង ប្រទេសខ្មែរ និង លាវ។ ទ្រឹស្តីនេះ វាគ្មានខុសអ្វីពីទ្រឹស្តី អាណានិគមនិយមនោះឡើយ។ តែនៅក្នុងទ្រឹស្តី ការពិតសង្គម នេះ អ្នកដឹកនាំ បក្សកុម្មុយនិស្ត វៀតណាម មិនបានលើក មកពិចារណា រកការពិត អំពី **ទ្វេចលនា**

(double mouvement)។ ដូចយ៉ាងគេដឹងថា នៅក្នុងពេល ដែលមាន កកើតគំនិត **ឋានានុក្រម** (hiérarchie) រវាងជាតិសាសន៍ តែងតែមានការកកើត នៃចលនាគំនិតប្រឆាំងនឹងវាវិញជានិច្ច ហេតុនេះឯង បានជាលទ្ធិអាណានិគមទទួល បរជ័យ រហូតរលាយអស់នៅក្នុងពិភពលោកនេះ។ បរាជ័យនេះបញ្ជាក់ឲយើញថាគ្មាន មនោគមវិជ្ជា ណាមួយ ឥតអាចដូរបាននោះឡើយ តែក៏គ្មាន មនោគមវិជ្ជា ណាមួយគ្មានកំណត់ ច្បាស់លាស់ នូវ **លំដាប់សង្គម** (ordre social) របស់ខ្លួន នោះដែរ។ ទ្វេចលនានេះវា ផ្លាស់ប្តូរ ពីអច្ចន្តភាពមួយ ទៅ អច្ចន្តភាពមួយទៀត (varier d'un extrême à l'autre) រហូតរកឃើញ នូវតុល្យាការមួយ ក្នុងពេលវេលាមួយ ទៅតាមភិនភាគនៃសង្គមមួយ។ នៅក្នុងទ្វេចលនានេះ គេអាចទុកមនោគមវិជ្ជា ជាការប្រយុទ្ធ និង ភាពតឹងគំនិត រវាងគូប្រជែង ដើម្បីការពារប្រយោជន៍រាងខ្លួន តែទំនាស់នេះ វាមានភាពធូរស្រាលច្រើន នៅក្នុងប្រទេសណាដែលយកលទ្ធិប្រជាធិបតេយ្យសេរីមកអនុវត្ត ឬ ក្នុងសង្គមជាតិណា ដែលមនុស្សលោក យកសីលធម៌ ជាច្បាប់សំរាប់រស់នៅ។

## III. មនោគមវិជ្ជា នៅក្នុងជីវិតនយោបាយ

យើង ដឹងថា ក្រោយពីប្រទេសខ្មែរទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៣មក មនោគមវិជ្ជាបានជ្រាបចូលក្នុងជីវិតនយោបាយខ្មែរ។ នៅក្នុងចំណោម **ពលរដ្ឋសកម្ម** (les citoyens actifs)ដែលអ្នកវិទូនយោបាយខ្លះ ឲឈ្មោះថា **បញ្ញាជននិយម**[7] (intellectualisme) នាំគ្នារួមគ្នា ជាក្រុម, ជាគណបក្សនយោបាយ, ជាក្លឹបគំនិត។ល។ ធ្វើសកម្មភាពនយោបាយ ដើម្បី កសាងជាតិ។ នៅក្នុងសកម្មភាពទាំងនោះ នៅក្នុងស្រុកខ្មែរ ក្នុងទស្សវត្សន៍ ១៩៤៦ មានបែងចែក មនោគមវិជ្ជា ជាក្រុមធំពីរ៖ អ្នកជាតិនិយម ឬអ្នកស្តាំនិយម និង អ្នកសង្គមនិយម ឬអ្នកឆ្វេងនិយម។ នៅក្នុងក្រុមពីរធំនេះ មានបែកចេញ ជាសាខា ច្រើនទៀត ដូចយ៉ាងនៅក្នុងក្រុម អ្នកជាតិនិយម មានបែកជាពីរ បរិវារសាខា៖ ក្រុម អ្នករាជាធិបតេយ្យ និង ក្រុម អ្នកប្រជាធិបតេយ្យសេរី។ ឯចំណែកនៅក្នុងក្រុម អ្នកសង្គមនិយម មានបែកជា ពីរ បរិវារសាខាដែរ៖ ក្រុមអ្នកប្រជាធិបតេយ្យនិយម និង ក្រុម អ្នកកុម្មុយនិស្តនិយម។ មនោគមវិជ្ជាដែលបានរៀបរាប់

[7] ពលរដ្ឋយកចិត្តទុកដាក់អំពីនយោបាយជាតិ។

អម្បាលម៉ាន ខាងលើនេះ មានសកម្មភាពនៅក្នុងគណបក្សនយោបាយសំខាន់បីៈ គណបក្សប្រជាធិបតេយ្យ, គណបក្សសេរីភាព និងគណបក្សប្រជាជន ឬកុម្មុយនិស្ត។ នៅក្នុងគណបក្សប្រជាធិបតេយ្យ ដែលយកលទ្ធិប្រជាធិបតេយ្យសេរីជាគោលនយោបាយ ប្រមូលផ្តុំបាន **បញ្ញាជននិយម** ជាអ្នកជាតិនិយម និយមលទ្ធិប្រជាធិបតេយ្យសេរី និងអ្នកសង្គមនិយម; ចំណែកគណបក្សសេរីភាព ប្រមូលផ្តុំបាន អ្នកជាតិនិយម ស្រឡាញ់ រាជាធិបតេយ្យនិយម; រីឯ គណបក្សប្រជាជន ប្រមូលផ្តុំ អ្នកកុម្មុយនិស្តនិយម។

នៅទីនេះ យើង មិនយកប្រវត្តិសាស្ត្រនយោបាយខ្មែរ មកអធិប្បាយទេ តែយើងគ្រាន់តែធ្វើសេចក្តីសង្ខេបថា ក្នុងការប្រយុទ្ធរវាងមនិគមវិជ្ជា ក្នុងជីវិតនយោបាយនៅក្នុងជំនាន់នោះ អ្នកដែលបានទទួលជ័យជំនះនៅទីបញ្ចប់នៅក្នុងឆ្នាំ១៩៥៦ គឺ សម្តេចសីហនុ។ កត្តាច្រើន ដែលនាំឲព្រះអង្គទទួលបានជ័យជំនះ ដូចយ៉ាងៈ

**១**. ចំនួន បញ្ញាជននិយម ឬ ពលរដ្ឋសកម្ម មានចំនួនតិចតួចណាស់ មិនអាចផ្តុំបានជាកម្លាំងម៉ាស៊ីន ទាញប្រជាជន ចេញពីទម្លាប់គំនិតខ្លាចអំណាច និង ទំនាមរស់នៅក្នុងសង្គមសក្តិភូមិបាននោះឡើយ។ ទោះបីនៅក្នុងជំនាន់នោះ មានសន្ទុះគំនិត លទ្ធិប្រជាធិបតេយ្យ-សេរី ចេញពីប្រជាជន យ៉ាងណាក៏ដោយ តែសន្ទុះនេះ ជាកម្លាំងផុយ ព្រោះវាគ្មានស្នូករឹងប៉ឹង និង ស្នូលធំ សំរាប់ ចិញ្ចឹម និង ការពារវា។

**២**. សម្តេចសីហនុ យកអំណាចផ្តាច់ការ ជាអាវុធប្រយុទ្ធនយោបាយ ដែលជាមធ្យោបាយមួយស្រួលអនុវត្តន៍ នៅក្នុងសង្គមខ្មែរ ដែលមានលក្ខណៈនៅពេលនោះ ជាសង្គមសក្តិភូមិ។ ជ័យជំនះ នេះជាជ័យជំនះពិតសំរាប់សីហនុ តែវាមិមមែនសំរាប់ប្រជាជាតិខ្មែរនោះទេ។ ដូចគ្នានឹងជ័យជំនះគណបក្សប្រជាជន និង សង្រ្គោះជាតិ ក្នុងការធ្វើសហការរួម គឺមិនសំរាប់ ប្រជាជនខ្មែរនោះដែរ។

បច្ចុប្បន្ននេះ មនោគមវិជ្ជា មាននៅក្នុងជីវិតនយោបាយខ្មែរ គឺជាមនោគមវិជ្ជាអំណាចផ្តាច់ការ បន្តពីនយោបាយ របស់ សពសីហនុ តែប៉ុណ្ណោះ ដែលអ្នកវិទូនយោបាយហៅថា **មនោគមវិជ្ជា-លំអាន** (idéologie-modèle)។ ដូចខ្មែរយើង ឮស្រាប់ហើយ នៅក្នុងជីវិតនយោបាយ សព្វថ្ងៃ អ្នកនយោបាយខ្មែរ គេប្រើតែពាក្យតែមួយគត់ គឺ គោរពឧត្តមគំនិតសពស្តេចសីហនុក្នុងនយោបាយរកការផ្សះផ្សារជាតិ ដើម្បីរក្សាសន្តិភាព តែអ្នកទាំងនោះ គាត់ឥតដឹងខ្លួនឯង

ផងថា គាត់កំពុងផ្សះផ្សារជាតិជាមួយនឹងអ្នកណា និង ដើម្បីអ្វី។ មនោគមវិជ្ជា-លំអាន នេះ ជា មនោគមវិជ្ជា បិនិវន្ត ដែលវាមានឥទ្ធពលខ្លាំងណាស់ទៅលើអាក្យកិរិយានយោបាយខ្មែរ នាំឲខ្មែរយើង រកពន្លឺថ្មីមិនឃើញសំរាប់ជីវិតនយោបាយ គឺពន្លឺលទ្ធិប្រជាធិបតេយ្យ។ ដូច្នេះ មនោគមវិជ្ជា-លំអាននេះ យើងអាចចាត់ទុកបានដែរថា ជា **មនោគមវិជ្ជា-ការឆ្លុះត្រឡប់** (idéologie-reflet) នៃសង្គមខ្មែរយើងសព្វថ្ងៃនេះឯង។ យើងអាចសន្និដ្ឋានបានថានៅស្រុកខ្មែរ មនោគមវិជ្ជា-លំអាន និង មនោគមវិជ្ជា-ការឆ្លុះត្រឡប់ ទុកជា **គិតិនិច្ចលនិយម** នោះឯង ព្រោះតាំងពីប្រទេសទទួលបានឯករាជ្យមក វាគ្មានផ្លាស់ប្តូរអ្វីនោះទេ នៅក្នុងជីវិតនយោបាយខ្មែរ ទោះបីយើងឃើញ មានដូរអាការក្រៅពិតប្រាកដ នៃសង្គមខ្មែរក៏ដោយ តែដួងរបស់វា គឺឋិតនៅដដែលជានិច្ច។

## IV. មនោគមវិជ្ជា និង គណបក្សនយោបាយ

សកម្មភាព នៃគណបក្សនយោបាយ មាននៅស្រុកខ្មែរ តាំងពីស្រុកបានឯករាជ្យមក ជាការឆ្លុះត្រឡប់ នៃអាក្យកិរិយានយោបាយ របស់អ្នកនយោបាយខ្មែរនោះឯង ដែលពួកគាត់បានទទួលឥទ្ធិពល អំពីមនោគមវិជ្ជាផង, អាការសង្គមផង និង ចរិតរបស់ជនខ្មែរផង ដូចបានអធិប្បាយខាងលើរួចមកហើយ។

មកដល់បច្ចុប្បន្នកាលនេះ យើង សង្កេតឃើញថា នៅក្នុងស្រុកខ្មែរមានគំនិតនយោបាយផ្តុំគ្នាជាបួនគ្រួសារៈ គ្រួសារអ្នកប្រពៃណីនិយម, គ្រួសារអ្នកកាលានុវត្តនិយម, គ្រួសារអ្នកប្រជាធិបតេយ្យសេរីនិយម និង គ្រួសារអ្នកអព្យាកតនិយម (អ្នកមិនច្បាស់) ជួនអាចទុកជាជនអ្នកខ្លាចនយោបាយ។ អាការនេះ វាគ្មានខុសផ្លែកអ្វី ពីអតីតកាលនោះដែរ ដែលនាំបង្កើតបានជារបបនយោបាយដឹកនាំខ្ជាប់ខ្ជួនមួយ គឺរបបនយោបាយផ្តាច់ការ។ របបនេះរស់ឥតមានប្រែប្រួល ដោយសារ មានការសម្រុះសម្រួលជានិច្ច រវាងអ្នកប្រពៃណីនិយម ជាមួយនិង អ្នកកាលានុវត្តនិយម រហូតមកដល់សព្វថ្ងៃនេះ ដូចយ៉ាង ការផ្សះផ្សា រវាង អ្នករាជានិយម ជាមួយនឹង បក្សប្រជាជន និង បក្សសង្គ្រោះជាតិ ដែលជាបក្សផ្តុំ អ្នកកាលានុវត្តនិយម។ ទង្វើនេះជាការផ្សះផ្សាមួយ ជួយ របបផ្តាច់ការឲកាន់តែរឹងប៉ឹងឡើង។

តាំងពីស្រុកខ្មែរ មានគណបក្សនយោបាយ ចាប់ពីឆ្នាំ១៩៤៦ មកដល់សព្វថ្ងៃ គណបក្សភាគច្រើន គ្រាន់តែមានរូបរាងជាក្រុមមនុស្ស មិនឋិតថេរ, កើតតែ**មួយកន្លង** (éphémère), មានសកម្មភាព រដាក់រដុប, គ្មានការរៀបចំមាំមួន,គ្មានកម្មវិធីនយោបាយ និង មនោគមវិជ្ជាពិតប្រាកដ។ សភាពការនេះ គឺបង្ហាញឲយើញថា គណបក្សនយោបាយ ជារូបភាព នៃការឆ្លុះត្រឡប់ នៃគ្រួសារនយោបាយ អ្នកកាលានុវត្តនិយម។ ខ្មែរទុកពួកប្រភេទនេះ ជាអ្នក «ឆ្អិតក្បាលស៊ីក្បាល ឆ្អិតកន្ទុយស៊ីកន្ទុយ»។ គណបក្សបែបនេះ គេច្រើនឲឈ្មោះវាថា ជាគណបក្សអ្នកចាំតែបោះឆ្នោត សំរាប់តែបំរើប្រយោជន៍ អ្នកដឹកនាំមួយក្រុមតូច តែប៉ុណ្ណោះ។ សួរថា គណបក្សប្រជាធិបតេយ្យ ដែលបានបង្កើតឡើងក្នុង១៩៤៦ ហើយរលាយសូន្យវិញក្នុងឆ្នាំ ១៩៥៦ ជាគណបក្សនយោបាយ មានតម្លៃខ្លួនជាគណបក្សនយោបាយពិតប្រាកដ ដែររឺទេ? បើយកថេរវេលា នៃជីវិត មានតែមួយទសវត្សរ៍ មកធ្វើយុត្តិកម្ម នៃគុណភាព របស់គណបក្សនេះ យើង ពុំអាចចាត់ទុកវា ថាជាបក្សនយោបាយ ប្រាកដប្រជាបានទេ ព្រោះរយះពេលតែដប់ឆ្នាំជា ថេរវេលា តិចណាស់សំរាប់ជីវិតនយោបាយ។ ផ្ទុយទៅវិញ យើង ពុំអាចមិនទទួលស្គាល់ថាគណបក្សនេះ គេគ្មានមនោគមវិជ្ជាពិតប្រាកដបាននោះឡើយ ព្រោះគេមានគោលដៅគេច្បាស់លាស់នៅក្នុងការតស៊ូនយោបាយរបស់គេ គឺះ ទាមទារឯករាជ្យពីអាណានិគមបារាំង, លើកតម្កើងលទ្ធិប្រជាធិបតេយ្យ និង ការពារឯកភាពទឹកដីជាតិ។ តែជាអកុសល នៅក្នុងគណបក្សនេះ អ្នកស្នេហាជាតិពិតប្រាកដ មានចំនួន តិចជាងពួកអ្នកកាលានុវត្តនិយម និង អ្នករាជានិយម ដែលនាំគ្នាដកខ្លួនទៅគាំទ្រសម្តេចសីហនុ នៅពេលដែលទ្រង់បង្កើតចលនាសង្គមរាស្ត្រនិយម។ ជ័យជំនះ សម្តេចសីហនុ ជាជ័យជំនះ ពួកអ្នកកាលានុវត្តនិយម នោះដែរ។

បើលើកយក គណបក្សសង្គ្រោះជាតិ មកសួរជាសំនួរ ថា តើយើងអាចចាត់ទុក ជាគណបក្សនេះ មាន មនោគមវិជ្ជា ការពារជាតិ ពិតប្រាកដ ដែរឬទេ ? ចម្លើយ គឺមាននៅក្នុងទង្វើដែលគណបក្សនេះ កំពុងប្រព្រឹត្តសព្វថ្ងៃនេះ គឺ ការចូលរួមធ្វើសហការ ជាមួយ គណបក្សប្រជាជន ដែលជាគណបក្ស ជា អ្នកបំរើផលប្រយោជន៍ បរទេស។

គួរលើកយកមកពិចារណាជាសង្ខេបអំពី អាការ «កាលានុវត្តនិយម» ដែលស្ទើរតែក្លាយជាវប្បធម៌ជាតិ នៅក្នុងជីវិតនយោបាយខ្មែរ ថាតើកត្តាអ្វីខ្លះ ដែលនាំឲអ្នកនយោបាយ ភាគច្រើន

អនេកប្បការ មានអាក្សកិរិយាបែបនេះ ?

កត្តាមានច្រើន ដូចយ៉ាងះ

**១. នយោបាយគ្មានប្រជាជន :**

នៅក្នុងជីវិតនយោបាយខ្មែរ អ្នកនយោបាយភាគច្រើន គាត់មិនដែលទុក ប្រជាពលរដ្ឋជា ដង្ហើមនៃសកម្មភាព នយោបាយ របស់គាត់នោះឡើយ។ ការចូលធ្វើសកម្មភាព របស់គាត់ គឺ ធ្វើឡើងក្នុងគោលបំណង រកផលប្រយោជន៍ផ្ទាល់ខ្លួន ច្រើនជាង រកផលប្រយោជន៍ទូទៅ ឬ ផលប្រយោជន៍ជាតិ។ អាក្សកិរិយានេះ គឺជាការឆ្លុះត្រឡប់ នូវអាការ នៃនយោបាយ មាននៅ ក្នុងស្រុកខ្មែរតាំងពីដូនតា មក គឺ «**អំណាចត្រួតត្រាដាច់មុខ**» : អ្នកនយោបាយ ជាអ្នកមាន អំណាច ត្រួត្រាប្រជាជន គ្មាន «**កាតព្វកិច្ចរកលទ្ធផល**» (obligation de résultat) ជូនប្រជា ជន។ ក្រុមអ្នកនយោបាយ ជាវណ្ណៈ, ជាបក្សពួក, ជាបន, ជាក្រុមគ្រួសារ, ជាហ្វូង សំរាប់រកផល ប្រយោជន៍ផ្ទាល់ខ្លួន ដូច្នេះនៅពេលបានអំណាច គេប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីរក្សា អំណាចគេជាដាច់ខាត។ ឧទាហរណ៍៖ នៅក្នុងស្រុកខ្មែរបច្ចុប្បន្ន ទាំងគណបក្សកាន់អំណាច និង គណបក្សថាខ្លួនជាប្រឆាំង រួបរួមគ្នា នៅក្នុងគោលបំណងរក្សាបុព្វសិទ្ធិ របស់បន ឬ ហ្វូង គេនោះឯង។

**២. យកចំណេះជាតម្លៃដាច់ខាត :**

ជាពិសេស នៅក្នុងចំណោមអ្នកចេះដឹង ព្រោះគាត់មានចំណេះសំរាប់ធ្វើការលក់ដូរ ទាញយក ប្រយោជន៍។ អ្នកចេះខ្មែរ ច្រើនមានគំនិតថា ចំណេះរបស់គាត់ ទោះបីគាត់ចូលធ្វើសកម្មភាព នយោបាយ នៅទីណាក៏ដោយ ចំណេះនេះ វានៅតែមានប្រយោជន៍ជានិច្ច ព្រោះវាជាចំណេះ បច្ចេកទេស ឬ វិទ្យាសាស្ត្រ។ ទស្សនៈបែបនេះ នាំឲគាត់ធ្វើការជ្រើសរើស ចូលធ្វើសកម្មភាព ទៅតាមកាលទេសៈ (opportunité) ដែលហុចមកឲគាត់។ ឧបមា បើនៅទីណា គាត់អាចទាញ យកផលប្រយោជន៍សំរាប់ខ្លួនឯងផ្ទាល់បាន គាត់ឥតរួញរា ជ្រើសរើស យកទីនោះជាមូលដ្ឋាន ទុកសំរាប់រកប្រយោជន៍។ តែយើងដឹងថា ប្រយោជន៍នៃចំណេះវិទ្យាសាស្ត្រ សំរាប់បំរើ នយោ-បាយ វាអាចមានវិបាកល្អឬ អាក្រក់ បើយកវាមកប្រើនៅទីល្អ វាកើតជាផលល្អ បើយកវាមក ប្រើនៅទីមិនល្អ វាក៏នាំបង្កើតផលមិនល្អ ដូច្នេះការយកចំណេះជាតម្លៃដាច់មុខ គ្មានស្គាល់ នូវ អ្វីជា កុសល និង អកុសល ជាគ្រោះថ្នាក់មួយដល់ខ្លួនឯងផង និង ដល់ប្រទេសជាតិផង។ តែ

បើគ្មានកាចេះដឹងសោះ ក៏ជាគ្រោះថ្នាក់មួយដែរ ព្រោះអវិជ្ជា វាជាអាហារចិញ្ចឹម អកុសល។

**៣. យកកំហឹងជាមាគ៌ា :**

ជាទូទៅ ការចូលធ្វើសម្មភាពនយោបាយ ច្រើនតែ **ភឿនចិត្ត** (motivation) តាមកំហឹងគ្មានការពិចារណា តែគេ ដឹងថា កំហឹងនេះ ជាវិចារណញ្ញាណ (raison) គ្មានការអប់រំ ក្នុងភារៈជាធម្មជាតិ របស់មនុស្ស។ ការភឿនចិត្តបែបនេះ ជាភ្លើងចំបើង ឆេះជាមហាអគ្គី តែឆាប់រលត់ ឆេះក្នុងកាលៈទេសៈមួយ ដែលអាចឲវាឆេះបាន តែគ្មាន លក្ខណៈ ជាភ្លើង ចាំងចេញពន្លឺបញ្ញា សំរាប់ខ្លួនឯងផង និង សំរាប់ជាតិផង។ តែគេដឹងដែរថា នៅចំពោះមុខ អំពើអយុត្តិធម៌ បើបុគ្គលណាគ្មានកំហឹងសោះ ក៏ពុំអាច ភឿនចិត្ត ឲដើបប្រឆាំង នឹងអំពើអយុត្តិធម៌ នោះបានដែរ។ កំហឹងប្រជាជន ប្រឆាំងនឹងអំពើអយិត្តិធម៌ ជាភ្លើងនៃបដិវត្តន៍ តែជាភ្លើងសំរាប់តែដុតកំទេចនូវអ្វីៗ ដែលជាអំពើចង្រៃសំរាប់ប្រជាជាតិ ដើម្បីសេចក្តីចំរើន ដល់មនុស្សជាតិ។

**៤. អាក្បកិរិយារបស់ខ្មែរ :**

អាក្បកិរិយា របស់ខ្មែរតាំងពីយូរយាមកហើយ គឺ ខ្លាចអំណាចអ្នកដឹកនាំជាតិ។ ចេតសិកភាព (mentalité) បែបនេះឯង ដែលធ្វើឲខ្មែរយើង ក្លាយស្រួលជា អ្នកកាលានុវត្តនិយម ព្រោះបើមានកាលៈទេសៈណាមួយ ដែលអ្នកដឹកនាំជាតិ គេហុចឲខ្លួន គឺច្បាស់ជាខ្លួនទទួល ដោយខ្លាចផង ដោយសប្បាយផង ឥតយកប្រាជ្ញា មកធ្វើជាជញ្ជីង សំរាប់ថ្លឹងមើលខុសត្រូវ គិតតែធ្វើគណនា (calculer) ប៉ាន់ប្រមាណ រកផលប្រយោជន៍តែប៉ុណ្ណោះ។

**៥. ភាពរមិនប្រាកដ របស់ វរជនខ្មែរ :**

វរជនខ្មែរ គាត់ច្រើនតែចូលធ្វើសកម្មភាពនយោបាយ មិនមែនដើម្បីបំរើនយោបាយ តែដើម្បី យកនយោបាយ ជាឧបករណ៍ បំរើខ្លួនគាត់។ ក្នុងគោលបំណងនេះ សកម្មភាពនយោបាយ បានទៅជាអាជីព របស់វរជន (élite) ខ្មែរ។ ហេតុនេះឯង បានជាមានការបែកគ្នា ក្នុងជីវិតនយោបាយខ្មែរ រវាង វរជននយោបាយ នឹងប្រជាជន។ ឧទាហរណ៍ ជាក់ស្តែង គឺការពាក់ងារជា «ឯកឧត្តម» នៃវរជននយោបាយ សំរាប់បញ្ជាក់នូវភាពខ្ពង់ខ្ពស់របស់ខ្លួន លើប្រជាជន។ ភាពខ្ពង់ខ្ពស់នេះ ជាធម្មនុរូប របស់វរជន សំរាប់ ជិះជាន់ប្រជាជន រកផលប្រយោជន៍ផ្ទាល់។ ក្នុង មានសិកភាព (mentalité) បែបនេះ ជាកត្តាបង្កើត វណ្ណៈអ្នកដឹកនាំជាតិបិទទ្វា គិតតែបំរើប្រយោជន៍វណ្ណៈតែប៉ុណ្ណោះ។ យើងប្រើពាក្យ «វណ្ណៈ» គឺចង់បង្ហាញថា សមាជិក

នៃវណ្ណៈមាន **សភាគភាព** (homogénéité) មាន **សម្បជញ្ញ** (conscience)ជាក្រុមដើម្បីរក ប្រយោជន៍រួម។ វណ្ណៈ នៃវរជននយោបាយនេះឯង ជា ក្រុមអ្នកកាលានុវត្តនិយម រស់យក សកម្មភាព នយោបាយ ជាអាជិព។

កត្តាសំខាន់ៗ ទាំងឡាយ ខាងលើនេះឯង ជាទ្វាបើកចិត្ត ជនខ្មែរ ឲមាននិន្នាការ ក្លាយស្រួល ទៅជា អ្នកកាលាននុវត្តនិយម ដែលជាអក្សកិរិយា នាំឲជាតិខ្មែរជួបប្រទះតែទុក្ខលំបាកជា និច្ច។ ប្រជាជាតិ ជួប អនុគ្រោះ គឺជាជង្រុក របស់មនុស្សពាល ដែលជាអ្នកឆ្លៀត រកផល ប្រយោជន៍ផ្ទាល់ យ៉ាងងាយស្រួលបំផុត លើអ្នកជា។ សព្វថ្ងៃនេះ នៅក្នុងចំណោមអ្នកនយោ បាយខ្មែរ, ចំនួនខ្មែរពាល មានច្រើនលើសលុប រលុបខ្មែរអ្នកជា ដែលនាំឲប្រជាជាតិ កើតជម្ងឺ មហារីក ពិបាករកថ្នាំសំរាប់ព្យាបាលរោគ។

## សេចក្តីសន្និដ្ឋាន

អាក្សកិរិយានយោបាយ របស់អ្នកដឹកនាំជាតិ និង អ្នកនយោបាយ សព្វថ្ងៃនេះ គឺជា **ការឆ្លុះ ត្រឡប់** នៃ ទម្ងន់ នៃការពិសោធន៍របស់ខ្លួន ដែលខ្លួនធ្លាប់ជួបប្រទះ គឺ អំណាចផ្តាច់ការ ; នៃ ទម្ងន់ នៃឥទ្ធពលសង្គម គឺសង្គមសកក្តិភូមិ ; ទម្ងន់ នៃឥទ្ធពល នៃកត្តាជីវសាស្ត្រ គឺ ការ រស់នៅ នៅក្នុង សេចក្តីអត់ឃ្លាន, សេចក្តីខ្លាចអំណាច (អំណាចរដ្ឋ និង អំណាចប្រពៃណី) និង អកម្មភាព ក្នុង កិច្ចការសាធារណៈ និង កិច្ចការរដ្ឋ។

ចំពោះបុគ្គល ឥទ្ធពលសំខាន់ពីរ មានមកលើខ្លួន គឺ ទី១. ស្ថាប័នបឋមៈ គ្រួសារ និង ការអប់រំ នៅក្នុងគ្រួសារ។ ខ្មែរច្រើននិយាយថា«ស្លឹកឈើមិនដែលជ្រុះឆ្ងាយពីគល់» ; ទី២.ស្ថាប័នមធ្យមៈ ប្រព័ន្ធ នៃតម្លៃ, មនោគមនវិជ្ជានយោបាយ, គតិយុត្តនិង សីលធម៌។ ស្ថាប័នទាំងពីរនេះឯង ជាមូលដ្ឋាន នៃបុគ្គលិកលក្ខណៈ របស់បុគ្គល ដែលជាសម្បទា នៃនិម្មិតកម្ម អាក្សកិរិយានយោ បាយ។

ចំពោះប្រជាពលរដ្ឋខ្មែរ, ទោះបី រស់នៅ តាមការវិវឌ្ឍន៍ នៃមនុស្សជាតិ ប៉ុន្តែតែងតែជួបប្រទះ ជានិច្ចនូវវិបត្តិសង្គម, វិបត្តិនយោបាយ និង វិបត្តិសីលធម៌ បន្តគ្នាជានិច្ច នាំឲខ្លួនបាត់ ការ រកទិសល្អមួយសំរាប់ ការរស់នៅរបស់ខ្លួន។ ត្រីវិបត្តិនេះ ជាកត្តានាំឲប្រជាជាតិខ្មែរ ធ្លាក់ក្នុង អត្តង្គត រំលាយ **អង្គបដិបក្ខ** (anticorps) សំរាប់ការពារជាតិសាសន៍ខ្មែរ។ វប្បធម៌រុងរឿងខ្មែរ

ក្លាយ **លើសលស់** (plus ou moins) ទៅជា ទំនាមទំលាប់និច្ចល លែងមានលទ្ធភាព ធ្វើ **បុនភាវកម្ម**(régénérer) ដើម្បីផ្លាស់ ទម្រង់ខ្លួនជាថ្មី ឲទាន់សម័យ។ ខ្មែរយើងគួរលើកយកមកពិចារណាដែរថា ក្រោយពីសម័យមហានគរមក តើយើងមានសមិទ្ធិកម្មអ្វីខ្លះ ដែលយើង អាចចាត់ទុកថាជា **កម្លាំងខ្មែរថ្មី** (renouveau khmer) ក្នុងវិស័យដឹកនាំជាតិ ?

ទោះបីខ្មែរយើង នៅតែយក សម័យមហានគរ មកធ្វើជាយោង សំរាប់ រំលឹក អំពី ជាតិខ្មែររុងរឿង តែយើងដឹងច្បាស់ថា អ្នកដឹកនាំជាតិខ្មែរជំនាន់នោះ គេរមែងទុកប្រជារាស្ត្រ ជា «កម្លាំង» សំរាប់ធ្វើពលកម្ម ដើម្បីប្រយោជន៏ខ្លួនគេ ឬ ជា «សត្វ-ធាតុ» ថោកទាប ដែលគេ ទុកប្រើដាច់ថ្លៃ តែប៉ុណ្ណោះ។ ការមើលងាយ ប្រជារាស្ត្រ ពីរជ្ជកាលមួយ ទៅរជ្ជកាល នាំឲប្រជាជាតិ ចុះដុនដាប វិនាសអន្តរាយ ឯប្រជារាស្ត្រវិញ ក៏ទទួលទុក្ខវេទនា មិនដែលស្បើយសោះ។ នយោបាយ ប្រើកម្លាំងរាស្ត្របែបនេះ អាចមានប្រសិទ្ធិភាព តែមួយរយៈពេលតែប៉ុណ្ណោះ ព្រោះថា កម្លាំង វាតែងតែ រលត់ ដោយការ ហត់នឿយ ដូច្នេះមានតែបញ្ញា (ការចេះដឹងច្បាស់ នូវសេចក្តីពិត) របស់មនុស្សខ្មែរទេ ដែលអាច ថែររក្សាស្រុកខ្មែរទាំងមូលបាន ដែលខ្មែរសំគាល់ថា ជា **បារមីប្រចាំបុគ្គលម្នាក់ៗ** សំរាប់ កសាងប្រជាជាតិ ឲបានចំរើនខ្ពង់ខ្ពស់។ បារមីនោះ គឺ ការព្យាយាម, សេចក្តីអត់ធន់, សច្ចះធម៌, មេត្តាធម៌ ដែល ជាសីលធម៌ សំរាប់មនុស្សខ្មែរ។ តែគុណសម្បត្តិទាំងនេះ អ្នកដឹកនាំជំនាន់ចាស់ មិនយកមកទុកជា**ជោគ** (atout) ហើយខំថែររក្សា ដើម្បីសេចក្តីរុងរឿងនៃជាតិខ្មែរ តែបែជាធ្វើ នយោបាយ ទុកតែកម្លាំងកាយខ្មែរ សំរាប់ប្រើ ដើម្បីឲមនុស្សខ្មែរ នៅល្ងិតល្ងង់ ក្នុងគោលបំណង ស្រណុកត្រួតត្រា។ កង្វះ លើកបារមីមនុស្សខ្មែរនេះហើយ ដែលនាំឲជាតិធ្លាក់ទៅក្នុងអត្ថង្គត នាំឲវិបត្តិទាំងបីយ៉ាង ដែលយើង បានរៀបរាប់ខាងលើនេះ នៅមានជីវិត ដដែលនៅក្នុងប្រជាជាតិខ្មែរ។ មកដល់បច្ចុប្បន្នកាលនេះ ខ្មែរយើងឥតអាចបង្កើត កម្លាំងខ្មែរថ្មី បាន ព្រោះអាក្បកិរិយា អ្នកដឹកនាំជាតិ គ្មានមានការដូរបន្តិចនោះឡើយ។ សួរថា ចុះហេតុ ខ្មែរនៅតែរង់ចាំជានិច្ច ដោយគ្មានសង្ឃឹម នូវឆន្ទះល្អ របស់អ្នកដឹកនាជាតិ ? ចម្លើយគឺថា មនុស្សខ្មែរ រស់នៅជានិច្ចនៅក្នុងទម្ងន់ឥទ្ធិពល ដែលយើងបានបរិយាយ នៅខាងលើនេះ។

តែមកដល់ដំណាក់ការ ដែល ប្រជាជាតិ ត្រូវអាប់អោនរស្មី បាត់បង់កិត្តិយសនិង សេចក្តីសុខសាន្ត ដោយអ្នកដឹងនាំជាតិ គ្មានគុណសម្បត្តិ ក៏នៅមានខ្មែរយើងខ្លះ ស្រែកសុំឲ ហ៊ុន-សែន

ប្តូរអាក្សកិរិយា ដើម្បីរំដោះ ឬ សង្គ្រោះជាតិ ពីគ្រោះថ្នាក់ដល់អាយុជីវិតជាតិ។ នេះហើយ ជា សុបិនជានិច្ច ឬ ជាការពិត របស់ខ្មែរ !

ហ៊ុន-សែន, សម-រង្ស៊ី និង កែម-សុខា គេមិនដូរ អាក្សកិរិយា របស់គេ ជាដាច់ខាត បើខ្មែរ យើង «ចេះត្រឹមតែសុំ ឲគេដូរ»។ បើខ្មែរយើងមិនដូរអាក្សកិរិយា ជាប្រជាពលរដ្ឋ តែងតួ ខ្លួន (stéréotype) ជា «អ្នកខ្លាចអំណាច» ឬ «ជឿផ្កាប់មុខ» ទៅលើ អ្នកដឹកនាំ ខ្មែរយើង នៅតែ រស់នៅ ក្នុងទុក្ខវេទនាជានិច្ច។

ចាស់បុរាណខ្មែរ ចារទុកសំរាប់ដាស់ស្មារតីកូនខ្មែរថា៖ សៀម មិនចោលក្បួន, យួន មិនចោល ពុត ឯចំណែក ខ្មែរ មិនចោលចែចូវ។ ការបំពាក់ នូវការតែងតួ ដល់ប្រជាពលរដ្ឋទាំងបីនេះ, បុព្វបុរសខ្មែរយើង លោកមានគោលបំណងទូន្មាន រាល់កូនខ្មែរ ឲបោះបង់ចោល នូវបុព្វអាក្ស កិរិយាខ្លួន ដែលនាំឲខ្មែរយើង ចាញ់កល ជានិច្ច ប្រជាពលរដ្ឋ ដែលជាអ្នកជិតខាងខ្លួន ព្រោះ គេធ្វើអ្វីមួយ យកបញ្ញា ជារបៀប ឯចំណែកខ្មែរយើងវិញ តែងតែយក របៀប ព្រាវ ឬ សិន មកអនុវត្តន៏។ ឧទាហរណ៏៖ តើខ្មែរណាម្នាក់ មិនដឹងថា យួនកំពុងប្រើពុត សំរាប់លេបទឹក ដីខ្មែរ តែនៅចំពោះមុខ គោលបំណងនេះ សម-រង្ស៊ី/កែម-សុខា នាំខ្មែរយើង ឲយក របៀប ព្រាវ ឬ សិន មកធ្វើជាមធ្យោបាយ ការពារជាតិទៅវិញ។ នេះហើយ អាក្សកិរិយានយោបាយ អ្នកដឹកនាំខ្មែរ !

ថ្ងៃទី២៣ កញ្ញា ឆ្នាំ ២០១៤

ឧប-សង្ហា